Declassified to Public
12 June 2020

លេខ៖ D304/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| ឯកសារបកប្រែ |
|---|
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 10-May-2016, 14:46 |
| CMS/CFO: Sann Rada |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្តី ផ្តល់ធនធានបន្ថែម

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីយឹម ទិត្យ**

សូ មូស្សេន្ទី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គភាពគាំពារការការពារក្តី**

**ការិយាល័យរដ្ឋបាល**

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ខ្ញុំបានស្នើអង្គភាពគាំពារការការពារក្តី ("អ.គ.ក") រៀបចំកិច្ចប្រជុំមួយជាមួយនឹងមេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") ដើម្បីរកដំណោះស្រាយចំពោះការផ្តល់ធនធានបន្ថែមដែលមេធាវីការពារក្តី បានស្នើ នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦[1]។ ខ្ញុំបានស្នើថែមទៀតថា អ.គ.ក និងមេធាវីការពារក្តី ត្រូវរាយការណ៍ជូនខ្ញុំ អំពីលទ្ធផលនៃកិច្ចប្រជុំនេះ[2]។

៣. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានដាក់របាយការណ៍របស់ខ្លួន ហើយនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ អ.គ.ក បានដាក់របាយការណ៍របស់ខ្លួន (តទៅនេះ ហៅកាត់រួមថា"របាយការណ៍")[3]។

## II. ពិភាក្សា

៤. បន្ទាប់ពីបានពិចារណាព័ត៌មាននៅក្នុងរបាយការណ៍ ខ្ញុំ ស្នើ អ.គ.ក ផ្តល់ជូនមេធាវីការពារក្តីឲ្យបានឆាប់បំផុតតាមការជាក់ស្តែងនូវបុគ្គលិកច្បាប់បន្ថែម ដូចបានបញ្ជាក់នៅក្នុង*សំណើបន្ទាន់សុំធនធានបន្ថែម*[4]។ ជាដំបូង ការតែងតាំងបុគ្គលិកច្បាប់បន្ថែមតាមសំណើនេះ នឹងមានកិច្ចសន្យាការងាររហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយអាចបន្តកិច្ចសន្យាបាន

---

[1]សំណុំរឿង 00៤ ឯកសារ D304/4 *ដីកាសម្រេចបន្ថែមលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យ អ.គ.ក ផ្តល់ធនធានបន្ថែម* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ("ដីកាសម្រេចបន្ថែម") កថាខណ្ឌ ២១។

[2]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២២។

[3]សំណុំរឿង 00៤ ឯកសារ D304/5 *របាយការណ៍បន្ទាន់ស្តីពីកិច្ចប្រជុំរបស់មេធាវីការពារក្តី អោ អាន ជាមួយនឹង អ.គ.ក យោងតាមដីកាសម្រេចបន្ថែមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យ អ.គ.ក ផ្តល់ធនធានបន្ថែម(D304/4)* ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៦។ សំណុំរឿង00៤ ឯកសារ D304/6 *របាយការណ៍របស់ អ.គ.ក ផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងសំណើរបស់មេធាវីការពារក្តី អោ អាន សុំធនធានបន្ថែម* ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦។

[4]សំណុំរឿង 00៤ ឯកសារ D304 *សំណើបន្ទាន់សុំធនធានបន្ថែម* ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦ កថាខណ្ឌ ១៨។

ប្រសិនបើតម្រូវការនៃកិច្ចស៊ើបសួរ និងការការពារសិទ្ធិរបស់ អោ អាន ត្រូវតម្រូវឲ្យបន្តកិច្ចសន្យានេះ។

៥. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៦. **ស្នើ** អ.គ.ក ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីតែងតាំងអ្នកប្រឹក្សាច្បាប់អន្តរជាតិជាន់ខ្ពស់ម្នាក់ និងអ្នកប្រឹក្សាច្បាប់អន្តរជាតិជាន់ទាបម្នាក់ ឲ្យបានឆាប់បំផុតតាមការជាក់ស្តែង ដើម្បីជួយមេធាវីការពារក្តី រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយអាចបន្តកិច្ចសន្យាការងារថែមទៀតប្រសិនបើតម្រូវការនៃកិច្ចស៊ើបសួរ ត្រូវតម្រូវឲ្យបន្តកិច្ចសន្យាការងារនេះ។

៧. **ស្នើ** អ.គ.ក ជូនដំណឹង ស.ច.ស ភ្លាមៗអំពីកាលបរិច្ឆេទចាប់ផ្តើមការងាររបស់អ្នកប្រឹក្សាថ្មីទាំងពីររូបនេះនៅពេលដែលទទួលបានព័ត៌មានបែបនេះ។

៨. **នៅទទួលពិនិត្យ** បញ្ហានេះ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d’instruction International**